00933645

E293

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 28 / 06 / 2013
ម៉ោង (Time/Heure) : 13:10
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អនុស្សរណៈ-អង្គជំនុំជម្រះសាលាដំបូង

**សាធារណៈ / Public**

**ជូនចំពោះ÷** **ភាគីនៃសំណុំរឿង ០០២** ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៣

**ពី÷** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន÷** **លោក /លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង, អង្គភាពគាំពារសាក្សី និងអ្នកជំនាញ**

**កម្មវត្ថុ÷** **សេចក្ដីសម្រេចលើសំណើសុំវិធានការការពារទាំងអស់នៅក្នុងសំណុំរឿង ០០២/០១ និងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ស សារិន សាជាថ្មី និងបង្គាប់ឲ្យមានការវាយតម្លៃជាផ្លូវការមួយពីតម្រូវការចាំបាច់សម្រាប់វិធានការការពារ (ឯកសារ E286)**

*សេចក្ដីផ្ដើម*

១. នៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះបានទទួលសំណើសុំវិធានការការពារសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១០ រូប (ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-18, TCCP-19, TCCP-62, TCCP-86, TCCP-87, TCCP-104, TCCP-109, TCCP-176, TCCP-177 និង TCCP-178)។ សំណើទាំងនេះត្រូវបានធ្វើឡើយដោយសហព្រះរាជអាជ្ញា ឬសហមេធាវីនាំមុខ ទាក់ទងនឹងបញ្ជីឈ្មោះសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដំបូងដែលភាគីបានស្នើសុំកោះហៅឲ្យផ្ដល់សក្ខីកម្មនៅសវនាការ (ឯកសារ E9/4.3.1, E9/4.6, E9/4/3.3, E9/4/3.5, E9/4/3/3 និង E9/4/3/3.1)។

២. អង្គជំនុំជម្រះបានកំណត់អត្តសញ្ញាណដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦ រូបបន្ថែមទៀត ដែលបានគូស បញ្ជាក់អំពីតម្រូវការឱ្យមានវិធានការការពារនៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះរបស់ពួកគាត់ (ពាក្យសុំ ដែលត្រូវទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី) ដោយភាគច្រើន ពុំមានបញ្ជាក់លម្អិតអំពីប្រភេទនៃ វិធានការការពារដែលត្រូវបានស្នើសុំ ឬមូលហេតុនៃតម្រូវការឱ្យមានវិធានការការពារឡើយ។ ដោយ ហេតុថាគ្មានភាគីណាមួយបានស្នើសុំស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះនៅសវនាការ ហេតុនេះ បុគ្គលទាំងនេះពុំត្រូវបានដាក់រហស្សនាម និងត្រូវបានកំណត់អត្តសញ្ញាណជំនួសវិញដោយ លេខយោងឯកសារនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (គឺ D22/1749, D22/2404, D22/ 2441, D22/2585, D22/2649 និង D22/3246)។

៣. អង្គជំនុំជម្រះក៏បានទទួលសំណើមួយពីសហព្រះរាជអាជ្ញាសុំឱ្យវាយតម្លៃអំពីតម្រូវការឱ្យមានវិធាន ការការពារសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន (TCCP-186) ដែលបានផ្តល់សក្ខីកម្មនៅក្នុង សំណុំរឿង ០០២/០១ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ និងស្នើសុំកោះហៅគាត់សាជាថ្មី សម្រាប់ការសួរសំណួរនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E286)។ មេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងសំណើសុំកោះហៅជាថ្មីនេះ (ឯកសារ E286/1)។

***វិធានការដែលអង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងអង្គជំនុំជម្រះ បានអនុវត្តមកទល់នឹងបច្ចុប្បន្ន ទាក់ទងនឹងវិធានការការពារ***

៤. ទាក់ទងនឹងសំណើសុំវិធានការការពារទាំងអស់ អង្គជំនុំជម្រះបានស្នើសុំឱ្យអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ធ្វើការវាយតម្លៃអំពីហានិភ័យដោយសម្ងាត់បំផុតចំពោះបុគ្គលខាងលើដោយអនុលោម តាមវិធាន ២៩(៣) នៃវិធានផ្ទៃក្នុង ដោយពិគ្រោះជាមួយមេធាវីតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទាំងនេះ។ ក្រោយពេលចេញអនុស្សរណៈនេះ ការវាយតម្លៃទាំងនេះ ព្រមទាំងសំណើសុំមុនៗទាំងអស់ ទាក់ទងនឹងវិធានការការពារ នឹងត្រូវជូនដំណឹងទៅភាគីទាំងអស់។ អង្គភាពគាំពារសាក្សី និងអ្នក ជំនាញ ក៏បានធ្វើការស៊ើបសួរផ្សេងៗមួយចំនួន ដើម្បីឆ្លើយតបទៅនឹងបញ្ហានានាដែលបានលើកឡើង នៅពេលសវនាការ (តាមសំណើរបស់អង្គជំនុំជម្រះ ឬតាមគំនិតផ្តួចផ្តើមរបស់ពួកគាត់ (*សូមមើល ឧទាហរណ៍* ឯកសារ E219/3 ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ១៥)) ប៉ុន្តែពុំមានសំណើ ណាមួយត្រូវបានចាត់ទុកថាផ្តល់ឱ្យនូវវិធានការការពារ ឬសមនឹងទទួលបាននូវការអន្តរាគមន៍ដ៏សកម្ម

របស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

៥. ស្របតាមទម្លាប់អនុវត្តរបស់តុលាការអន្តរជាតុបនីយកម្មផ្សេងៗ បុគ្គលនានាដែលត្រូវបានកោះហៅដើម្បីផ្តល់ភស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ ត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងតុលាការមុនពេលផ្តល់សក្ខីកម្មរបស់ពួកគាត់ តាមរយៈតែឈ្មោះរហស្សនាមរបស់ពួកគាត់ប៉ុណ្ណោះ ជាសំខាន់ដើម្បីការពារប្រឆាំងនឹងការរំខានពីសំណាក់សារព័ត៌មាន។ បន្ទាប់ពីការផ្តល់សក្ខីកម្មរបស់ពួកគាត់នៅក្នុងសវនាការជាសាធារណៈ បុគ្គលទាំងអស់នោះអាចត្រូវបានបញ្ចេញឈ្មោះរបស់ពួកគាត់នៅក្នុងតុលាការ។

*ក្របខណ្ឌគតិយុត្តិ*

៦. អនុលោមតាមវិធាន ២៩(៣) នៃវិធានផ្ទៃក្នុង តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមសំណើ និងក្រោយពេលពិគ្រោះជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យមានវិធានការសមស្រប ដើម្បីការពារជនរងគ្រោះ និងសាក្សីដែលការបង្ហាញខ្លួនរបស់ពួកគាត់នៅចំពោះមុខអង្គជំនុំជម្រះ "អាចធ្វើឱ្យជីវិត ឬសុខភាពរបស់ពួកគាត់ ឬរបស់សមាជិកគ្រួសាររបស់ពួកគាត់ ឬសាច់ញាតិជិតស្និតរបស់ពួកគាត់ ស្ថិតក្រោមគ្រោះថ្នាក់ធ្ងន់ធ្ងរ"។ វិធានការការពារដែលស្ថិតនៅក្រោមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក រួមមាន ការប្រើប្រាស់ឈ្មោះរហស្សនាមនៅពេលហៅបុគ្គលដែលត្រូវបានការពារនៅក្នុងតុលាការ ការផ្តល់សក្ខីកម្មនៅក្នុងសវនាការជាអសាធារណៈ ឬតាមរយៈមធ្យោបាយពីចម្ងាយ និងការបំប្លែងសំឡេង ឬរូបរាងរបស់បុគ្គលនោះ (វិធាន ២៩(៤)នៃវិធានផ្ទៃក្នុង)។ ក្នុងករណីចាំបាច់ អង្គជំនុំជម្រះក៏អាចបង្គាប់ឱ្យមានការការពាររូបកាយរបស់ជនរងគ្រោះ ឬសាក្សីនៅក្នុងលំនៅដ្ឋានដែលមាន សុវត្ថិភាពនៅកម្ពុជា ឬបរទេស (វិធាន ២៩(៧) នៃវិធានផ្ទៃក្នុង))។

៧. វិធានការការពារត្រូវបានផ្តល់ឱ្យទៅតាមករណីនីមួយៗ នៅពេលដែលមានព័ត៌មាន ដើម្បីបញ្ជាក់អំពីហានិភ័យ ឬការគំរាមកំហែងអំពីព្យសនកម្មចំពោះអ្នកដាក់ពាក្យសុំ ឬសាច់ញាតិរបស់ពួកគាត់។ ការភ័យខ្លាចជាក់ស្តែងរបស់អ្នកដាក់ពាក្យសុំ ឬសាច់ញាតិរបស់ពួកគាត់ គឺត្រូវតែមានជាចាំបាច់ ព្រមទាំងអត្ថិភាពនៃយុត្តិកម្មសមស្របចំពោះការភ័យខ្លាចនេះ[1]។ នេះមានន័យថា ការយល់បែបអត្តនោម័តិរបស់

[1] *សំណុំរឿង ០០១, កាំង ហ្គេកអ៊ាវ,* សេចក្តីសម្រេចអំពីវិធានការការពារសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី, ឯកសារ E71, ថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០០៩, កថាខណ្ឌ ៧, *សំណុំរឿង ០០១, កាំង ហ្គេកអ៊ាវ,* សេចក្តីសម្រេចអំពីវិធានការការពារសម្រាប់ដើមបណ្តឹងរដ្ឋប្ប

អ្នកដាក់ពាក្យសុំតែមួយមុខ ពុំទាន់គ្រប់គ្រាន់សម្រាប់ឱ្យមានការផ្ដល់វិធានការការពារនោះទេ ហើយជាការចាំបាច់ត្រូវបង្ហាញអំពីហានិភ័យពិតប្រាកដនៃព្យសនកម្មរបស់អ្នកដាក់ពាក្យសុំ ឬក្រុមគ្រួសាររបស់គាត់[2]។ យុត្តិសាស្ត្រអន្តរជាតិពាក់ព័ន្ធបានទទួលស្គាល់ភាពងាយរងគ្រោះជាក់លាក់របស់ក្រុមមនុស្សមួយចំនួន ដូចជា បុគ្គលដែលផ្ដល់សក្ខីកម្មអំពីស្ថានភាពនៃអំពើហិង្សាផ្លូវភេទ ដែលបានអនុញ្ញាតឱ្យមានវិធានការការពារ ដូចជា ការធ្វើសវនាការមួយផ្នែកជាអសាធារណៈ[3]។ ប្រភេទនៃវិធានការការពារដែលត្រូវបានបង្គាប់ ត្រូវបានរៀបចំតម្រូវទៅតាមហានិភ័យជាក់លាក់ដែលអ្នកដាក់ពាក្យសុំ បានប្រឈម ដោយសហការជាមួយសមត្ថកិច្ចជាតិសមស្របទៅតាមការចាំបាច់។ នៅពេលវាយតម្លៃអំពីប្រភេទ និងកម្រិតនៃការការពារ ដែលត្រូវផ្ដល់ឱ្យ អង្គជំនុំជម្រះត្រូវតែថ្លឹងថ្លែងអំពីភាពធ្ងន់ធ្ងរនៃហានិភ័យដែលប្រឈមនឹងអ្នកដាក់ពាក្យសុំ វិធានការដែលសមស្របបំផុតដើម្បីដោះស្រាយហានិភ័យ និងការរំលោភណាមួយទៅលើសិទ្ធិរបស់ជនជាប់ចោទ។ ការវាយតម្លៃនេះត្រូវតែមានសំអាងហេតុ។

---

វេណី, ឯកសារ E2/62 និង ឯកសារ E2/89 និងសម្រាប់សាក្សីដែលមានរហស្សនាម KW-10 និង KW-24, ឯកសារ E135, ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០០៩, កថាខណ្ឌ ៣។ *សូមមើលផងដែរ សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Gatete, សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីស្នើសុំការការពារសាក្សី,* សំណុំរឿងលេខ ICTR-2000-61-I, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៧, កថាខណ្ឌ ២, *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Bagosora et al.,* សេចក្ដីសម្រេចលើសំណើរបស់ Bagosora ស្នើសុំការការពារសាក្សី, លេខសំណុំរឿង ICTR-96-7, ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៣, កថាខណ្ឌ ២, *រដ្ឋអាជ្ញា ទល់នឹង Stanisic and Simatovic,* សេចក្ដីសម្រេចអំពីវិធានការការពារសម្រាប់សាក្សីដែលមានរហស្សនាម DST-051 សម្រាប់ហេតុផលផ្ទាល់ខ្លួន, លេខសំណុំរឿង IT-03-69-T, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១, កថាខណ្ឌ ៤។

[2] *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Milosevic,* សេចក្ដីសម្រេចទីពីរលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំវិធានការការពារសម្រាប់សាក្សីដែលជាប្រភពរសើប, លេខសំណុំរឿង IT-02-54-T, ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០២, កថាខណ្ឌ ៧, *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Rukundo,* សេចក្ដីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំវិធានការការពារសម្រាប់សាក្សីដែលមានរហស្សនាម CCF, CCJ, BLS និង BLJ, លេខសំណុំរឿង ICTR-2001-70-T, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦, កថាខណ្ឌ ៣។

[3] វិធាន ២៩(៤)(ង)នៃវិធានផ្ទៃក្នុង, *សូមមើលផងដែរ សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Tadic,* សេចក្ដីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំវិធានការការពារសម្រាប់ជនរងគ្រោះ និងសាក្សី, លេខសំណុំរឿង IT-94-1-T, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៥, កថាខណ្ឌ ៤៦-៤៧, *រដ្ឋអាជ្ញា ទល់នឹង Delalic,* សេចក្ដីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំវិធានការការពារសម្រាប់សាក្សីរបស់រដ្ឋអាជ្ញាដែលត្រូវបានដាក់រហស្សនាម “B” ដល់ “M” , លេខសំណុំរឿង IT-96-21-T, ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៧, កថាខណ្ឌ ៤០-៤៥។

*សំណើសុំវិធានការការពារសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលភាគីបានស្នើសុំស្តាប់សក្ខីកម្មនៅសវនាការ*

៨. ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះបានស្នើសុំវិធានការការពារតែនៅក្នុងករណីដែលពួកគាត់ត្រូវបានកោះហៅដើម្បីផ្តល់សក្ខីកម្មប៉ុណ្ណោះ។ វិធានការដែលបុគ្គលទាំង ១០ រូបនេះស្នើសុំ បានរួមបញ្ចូលទាំងការផ្តល់សក្ខីកម្មនៅក្នុងសវនាការជាអសាធារណៈ ឬតាមរយៈប្រព័ន្ធសោតទស្សន៍ និងការកំណត់អត្តសញ្ញាណនៅក្នុងតុលាការតាមរយៈឈ្មោះរហស្សនាម។ បន្ទាប់ពីបានជួបជាមួយតំណាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-18, TCCP-62 និង TCCP-87 បានដកសំណើសុំវិធានការការពាររបស់ពួកគាត់ ហើយដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-104, TCCP-176, TCCP-177 និង TCCP-178 ក៏បានបង្ហាញឆន្ទៈក្នុងការផ្តល់សក្ខីកម្មនៅក្នុងសវនាការជាសាធារណៈ ប្រសិនបើពួកគាត់ត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្មនៅសវនាការ។ ដោយហេតុថាមិនមានដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់នៅក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំង ១០ រូបនេះ ត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១ ឡើយ ហេតុដូច្នេះ សំណើសុំវិធានការការពារទាំងអស់នេះនៅក្នុងសំណុំរឿង ០០២/០១ គឺជាសំណើសុំពុំចាំបាច់ឡើយ។

*សំណើសុំវិធានការការពារសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលភាគីពុំបានស្នើសុំស្តាប់សក្ខីកម្មនៅសវនាការ*

៩. ដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខឯកសារ D22/2585, D22/2441 និង D22/3246 បានដាក់សំណើសុំដកវិធានការការពារជាផ្លូវការរបស់ពួកគាត់ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណី D22/1749 បានបញ្ជាក់ទៅអង្គភាពគាំពារសាក្សីនិងអ្នកជំនាញថាគាត់មានបំណងក្នុងការដកសំណើសុំវិធានការការពារនេះ។ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលនៅសេសសល់ (D22/2404 និង D22/2649) មិនបានកំណត់អំពីអត្តសញ្ញាននៃហានិភ័យ ឬការភ័យខ្លាចដែលជាមូលដ្ឋាននៃសំណើទាំងនេះឡើយ ហើយពួកគាត់ក៏មិនបានគូសបញ្ជាក់ថាតើពួកគាត់ស្នើសុំវិធានការការពារជាក់លាក់អ្វីខ្លះនោះដែរ។ ពុំមានសេចក្តីលម្អិតនៅក្នុងសំណើទាំងនេះ ឬកាលៈទេសៈណាមួយដែលនាំឱ្យមានវិធានការការពារដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ ពីមេធាវីតំណាងរបស់ពួកគាត់ឡើយ។ ដូច្នេះ អង្គជំនុំជម្រះគ្មានលទ្ធភាពវាយតម្លៃអំពីលក្ខណៈនៃសំណើទាំងនេះ ឬភាពសមស្របជាមួយវិធាន ២៩ (៣) នៃ

វិធានផ្ទៃក្នុងឡើយ ហេតុនេះអង្គជំនុំជម្រះសម្រេចបដិសេធសំណើសុំទាំងនេះ។

***សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ស សារិន សាជាថ្មី (TCCP-186)***

១០. នៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មរបស់គាត់នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន បានគូសបញ្ជាក់ថាគាត់ភ័យខ្លាចការសងសឹកពីកងកម្លាំងខ្មែរក្រហម។ បន្ទាប់មក គាត់បានអះអាងថាគាត់ពុំអាចផ្តល់ព័ត៌មានបន្ថែមដល់អង្គជំនុំជម្រះបានទេ លើកលែងតែគាត់បានទទួលវិធានការការពារពេញលេញ ដូចជាការផ្តល់ការការពារពីនគរបាលរហូតដល់គាត់អស់ជីវិតទៅ (ប្រតិចារឹកថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០១៣ ទំព័រ ៣៧-៤២, ទំព័រ ៥២-៥៤)។

១១. នៅមុនពេលផ្តល់សក្ខីកម្មរបស់គាត់ ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ត្រូវបានអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ សាកសួរចំនួនពីរលើក ជាពិសេសទាក់ទងទៅនឹងសន្តិសុខរបស់គាត់ (ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១០ និងថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១១)។ ស សារិន បានប្រាប់អង្គភាពគាំពារសាក្សី និងអ្នកជំនាញថា គាត់ពុំមានក្តីបារម្ភអំពីសន្តិសុខរបស់គាត់ឡើយ ហើយគាត់យល់ព្រម និងអាចសហការយ៉ាងពេញលេញជាមួយនឹងអង្គជំនុំជម្រះ និងដកសំណើសុំវិធានការការពាររបស់គាត់វិញដោយស្ម័គ្រចិត្ត។ មន្ត្រីនៃផ្នែកការពារសាក្សីរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ មិនអាចកំណត់អត្តសញ្ញាណអំពីហានិភ័យជាក់លាក់ណាមួយដែលអាចនឹងកើតមានចំពោះដើមបណ្តឹងរដ្ឋប្បវេណីនេះឡើយ។ បន្ទាប់ពីមានសំណើរបស់ ស សារិន ដែលធ្វើឡើងនៅក្នុងតុលាការរួចមក អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានធ្វើការវាយតម្លៃជាថ្មីឡើងវិញលើដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បញ្ជាក់នៅក្នុងរបាយការណ៍របស់ខ្លួន ដែលនឹងត្រូវជូនដំណឹងដល់គ្រប់ភាគីក្នុងពេលឆាប់ៗនេះថា អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានជួបសន្ទនាជាច្រើនជាមួយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ បន្ទាប់ពីគាត់បានធ្វើការស្នើសុំរួចមក គាត់បានបញ្ជាក់ថា គាត់មិនបានឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងមេធាវីរបស់គាត់ ដឹងអំពីគោលបំណងស្នើសុំវិធានការការពារនៅក្នុងតុលាការឡើយ ពីព្រោះប្រសិនបើគាត់ពុំធ្វើដូច្នេះទេ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះជឿជាក់ថាគាត់នឹងមិនត្រូវបានគេកោះហៅឲ្យមកផ្តល់សក្ខីកម្មឡើយ។ ស សារិន បញ្ជាក់ថាគាត់មានការភ័យខ្លាចជាទូទៅអំពីលទ្ធភាពនៃការសងសឹកពីសំណាក់អតីតសមាជិកខ្មែរក្រហមដែលនៅរស់ ដែលនៅមានភក្តីភាពចំពោះមេដឹកនាំទាំងនោះ ហើយគាត់បញ្ជាក់ថាគាត់មិនបានត្រៀមខ្លួនដើម្បីផ្តល់ព័ត៌មាន

បន្ថែមជូនអង្គជំនុំជម្រះឡើយ លើកលែងតែអង្គជំនុំជម្រះផ្ដល់នូវវិធានការការពារជាក់លាក់ដល់គាត់ (ការផ្ដល់ជូននូវការការពារពីនគរបាលរហូតដល់គាត់អស់ជីវិត ឬផ្លាស់ទីលំនៅរបស់គាត់ និងក្រុមគ្រួសាររបស់គាត់ឱ្យទៅរស់នៅបរទេស)។ គាត់បានបញ្ជាក់បន្ថែមទៀតថា គាត់មិនមានបំណងទទួលបានវិធានការការពារណាមួយផ្សេងទៀត ដូចជាការផ្ដល់សក្ខីកម្មនៅក្នុងសវនាការជាអសាធារណៈឡើយ។

១២. ទោះបីជាមានក្ដីបារម្ភជាអត្តនោម័តដែលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ បានលើកឡើងយ៉ាងណាក៏ដោយ ក៏អង្គភាពគាំពារសាក្សី និងអ្នកជំនាញ មិនអាចកំណត់អំពីមូលដ្ឋានសត្យានុម័ត ឬជាក់ស្ដែងណាមួយចំពោះការភ័យខ្លាចទាំងនេះឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចថា វិធានការដែលដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើឡើងនោះ មិនអាចផ្ដល់ជូនបានឡើយ។

១៣. អង្គជំនុំជម្រះពិចារណាបន្ថែមទៀតថា ការកោះហៅ ស សារិន មកផ្ដល់សក្ខីកម្មសាជាថ្មីទំនងជាមិនអាចនាំមកនូវការបញ្ជាក់ការពិត ឬសម្រាប់ផលប្រយោជន៍យុត្តិធម៌ឡើយ។ ដោយសារតែដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញឆន្ទៈថាមិនអាចមកផ្ដល់សក្ខីកម្មជាថ្មីម្ដងទៀតទេ និងដោយសារតែ ស សារិន មិនអាចត្រូវបានបង្ខំឱ្យមកផ្ដល់សក្ខីកម្មបានឡើយ អនុលោមតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក (វិធាន ២៣(៤) នៃវិធានផ្ទៃក្នុង) ដូច្នេះសំណើរបស់សហព្រះរាជអាជ្ញាត្រូវបានបដិសេធ។

១៤. សេចក្ដីសម្រេចនេះគឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងសំណើ E286។